MEDIA ADVISORY

UNITED NATIONS HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER

សម្រាប់ទិវាពិភពលោកស្ដីពីយុត្តិធម៌សង្គម

ថ្ងៃសុក្រ ទី២០ ខែកុម្ភៈ ឆ្នាំ២០១៤

# យុត្តិធម៌សង្គមពង្រឹង សន្តិភាព សន្តិភាពធ្វើ ឲ្យមានយុត្តិធម៌សង្គម

**ទីក្រុងហ្សឺណែវ** (១៩ កុម្ភៈ ២០១៥) - សាររបស់អ្នកជំនាញការឯករាជ្យរបស់អង្គការសហប្រជាជាតិទទួលបន្ទុកលើកស្ទួយសណ្ដាប់ធ្នាប់ប្រជាធិបតេយ្យ និងសមធម៌អន្តរជាតិ លោក អាល់ហ្វ្រេដ ដឺ ហ្សាយ៉ាស *(Alfred de Zayas)* ដើម្បីប្រារព្ធធ្វើទិវាពិភពលោកស្ដីពីយុត្តិធម៌សង្គម នាថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៥។

"ទិវាពិភពលោកស្ដីពីយុត្តិធម៌សង្គម ត្រូវបានមហាសន្និបាតប្រកាសជាផ្លូវការឲ្យប្រារព្ធធ្វើនៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ ២០០៧ ដើម្បីអះអាងជាថ្មីអំពីមុខងាររបស់យុត្តិធម៌សង្គមក្នុងបង្ការជម្លោះ និងជំរុញឲ្យរដ្ឋ អង្គការអន្តររដ្ឋាភិបាលទាំងអស់ ព្រមទាំងសហគមន៍អន្តរជាតិ ឲ្យជម្រុញយ៉ាងសកម្មនូវការអភិវឌ្ឍសង្គម និងយុត្តិធម៌សង្គម ជាគ្រឹះនៃសន្តិភាព និងសន្តិសុខអន្តរជាតិដ៏យូរអង្វែង។"

បញ្ហាជាច្រើននាពេលបច្ចុប្បន្ននេះ មានប្រភពកើតចេញពីអយុត្តិធម៌សង្គម និងការរើសអើងទូទៅជាប្រព័ន្ធ។ វាជារឿងឥតប្រយោជន៍ដែលត្រូវរកឲ្យឃើញដើមចមនៃអំពើភេរវកម្មនៅក្នុងតំបន់ណាមួយនោះ ដោយសារថាសាសនាទាំងអស់គឺផ្អែកលើសេចក្ដីប្រាថ្នាជាសកលចង់បានសន្តិភាព និងសេចក្ដីថ្លៃថ្នូរនៃមនុស្ស។ ក្នុងចំណោមដើមចមទាំងឡាយ មានបញ្ហាអតុល្យភាពសេដ្ឋកិច្ច និងពាណិជ្ជកម្ម ប្រវត្តិនៃការធ្វើអន្តរាគមន៍ ការកេងប្រវ័ញ្ច និងភាពក្រីក្រតោកយ៉ាក។

ដំណោះស្រាយមិនអាចធ្វើទៅបាន តាមរយៈការដាក់ពង្រាយកម្លាំងទ័ពទេ ផ្ទុយទៅវិញ តាមរយៈការយល់ដឹងច្រើនទូលំទូលាយថែមទៀត អំពីបញ្ហាដែលជំរុញឲ្យមនុស្ស ជាពិសេសយុវជន យុវនារី មានការអស់សង្ឃឹម និងប្រព្រឹត្តអំពើហិង្សានោះឡើង។

វិបត្តិហិរញ្ញវត្ថុឆ្នាំ២០០៧-២០០៨ និងបន្តបន្ទាប់មកទៀត កើតមានជាពិសេសគឺជាវិបត្តិផ្លូវចិត្ត ដែលបណ្ដាលមកពីការកំណត់បញ្ហាអាទិភាពមិនបានត្រឹមត្រូវ ប្រតិបត្តិការហិរញ្ញវត្ថុដែលមិនមានទំនួលខុសត្រូវ និងការប្រគល់ឲ្យវិស័យឯកជនគ្រប់គ្រងលើទីផ្សារ។ ដំណោះស្រាយមិនត្រឹមតែមិនអាចដាក់វិធានការតឹងរ៉ឹងលើសេវាសង្គម

ដែលជាយឺកញយបំផុត បានបណ្តាលឲ្យមានភាពអត់ការងារធ្វើដ៏ច្រើន ដែលរិតតែធ្វើឲ្យអយុត្តិធម៌សង្គមកាន់តែធ្ងន់ធ្ងរ និងបានធ្វើឲ្យប៉ះពាល់ថែមទៀតដល់អ្នកទន់ខ្សោយ និងជនបាត់បង់ឱកាសស្រាប់ហើយនោះ។

ក្នុងចំណោមដំណោះស្រាយចាំបាច់ មានការបង្កើតឲ្យមានការងារធ្វើ និងហេដ្ឋារចនាសម្ព័ន្ធនានា តាមរយៈការវិនិយោគរបស់រដ្ឋាភិបាល និងវិស័យឯកជនជាគោលដៅ។ ប្រគល់ឲ្យរដ្ឋាភិបាល ជាអ្នកពង្រឹងអនុវត្តវិធានការតឹងរ៉ឹង ដោយធ្វើការកាត់បន្ថយចំនួនកងទ័ព និងទប់ស្កាត់មិនឲ្យមានសង្គ្រាម និងភាពប្រថុយប្រថានផ្សេងទៀតខាងយោធា ដែលធ្វើឲ្យអន្តរាយធ្ងន់ធ្ងរដល់មនុស្ស និងហិរញ្ញវត្ថុ។

សណ្តាប់ធ្នាប់សមធម៌អន្តរជាតិ មិនអាចកើតមានឡើយ ប្រសិនជាគ្មានយុត្តិធម៌សង្គម សេចក្តីថ្លៃថ្នូររបស់មនុស្ស និងការមិនរើសអើង ដែលជាបុរេលក្ខខណ្ឌសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច និងសង្គមប្រកបដោយចិរភាព។ កិច្ចព្រមព្រៀងពាណិជ្ជកម្ម និងវិនិយោគអន្តរជាតិត្រូវតែបានដឹងពីគោលដៅរួមមួយ គឺការធ្វើឲ្យសម្រេចបានយុត្តិធម៌សង្គមនៅទូទាំងពិភពលោក និងដើម្បីពង្រឹងបទដ្ឋានពលកម្មឲ្យស្របតាមអនុសញ្ញាពាក់ព័ន្ធរបស់អង្គការពលកម្មអន្តរជាតិ (ILO)។ តបមកវិញ ប្រការនេះតម្រូវឲ្យមានកិច្ចពិគ្រោះយោបល់ជាសាធារណៈពិតប្រាកដ និងបុរេសកម្ម ដោយរដ្ឋាភិបាលទាំងឡាយ និងភ្នាក់ងារពាក់ព័ន្ធទាំងអស់ ដើម្បីគិតគូរត្រឹមត្រូវដល់ផលប្រយោជន៍របស់ប្រទេសនានាដែលមិនចូលរួម ដែលមិនគួរត្រូវរងផលប៉ះពាល់អវិជ្ជមានដោយសារតែកិច្ចព្រមព្រៀងដែលផ្តល់ផលប្រយោជន៍ឲ្យតែប្រទេសមួយចំនួន ហើយប៉ះពាល់ដល់ប្រទេសជាច្រើននោះ។

សណ្តាប់ធ្នាប់ប្រជាធិបតេយ្យ និងសមធម៌អន្តរជាតិតម្រូវឲ្យមានកិច្ចពិគ្រោះយោបល់ពីសំណាក់ភាគីពាក់ព័ន្ធនានា និងការចូលរួមជាសាធារណៈពិតប្រាកដនៅថ្នាក់មូលដ្ឋាន ថ្នាក់ជាតិ និងថ្នាក់តំបន់។ សមាជិកសភាមានទំនួលខុសត្រូវជាពិសេសក្នុងការឃ្លាំមើល និងធានាចម្មានរូបប្រជាធិបតេយ្យនៃកិច្ចព្រមព្រៀងពាណិជ្ជកម្មអន្តរជាតិទាំងអស់ និងទប់ស្កាត់មិនឲ្យកើតមានការអនុម័តលឿនមុនកាលកំណត់ ដោយលទ្ធផលចុងក្រោយ ធ្វើឲ្យប្រាស់ចាកពីឆន្ទះរបស់ប្រជាពលរដ្ឋដែលពាក់ព័ន្ធ។

យុត្តិធម៌សង្គម និងការផ្តល់សិទ្ធិអំណាចដល់ក្រុមដែលប្រឈមនឹងហានីភ័យនៃការបាត់បង់ឱកាស ពង្រឹងរបៀបវារៈនៃអភិវឌ្ឍន៍ប្រកបដោយចិរភាព ក្រោយឆ្នាំ២០១៥ ហើយក៏ជាសមាសធាតុដ៏សំខាន់នៃកម្មវិធីសកម្មភាពឆ្ពោះទៅកាន់ការផ្លាស់ប្តូរនេះ ត្រូវបានជំរុញតាមរយៈការសន្យាជាផ្លូវការពីសំណាក់សហគមន៍អន្តរជាតិ ដើម្បីលុបបំបាត់ភាពក្រីក្រតោកយ៉ាក លើកកម្ពស់បទដ្ឋានសុខភាព និងការពារបរិស្ថាន ដែលជាកេរ្តិ៍រតករួមរបស់មនុស្សជាតិ។

ដោយមានការគាំទ្រពីការងាររបស់អង្គការពលកម្មអន្តរជាតិ (ILO) រួមទាំង របៀបវារៈការងារសមរម្យ ទិវាយុត្តិធម៌សង្គមបញ្ជាក់ពីសារៈសំខាន់ថា ទន្ទឹមនឹងសកលភាវូបនីយកម្ម និងការពឹងអាស្រ័យគ្នាទៅវិញទៅមកជា

អន្តរជាតិ បង្កើតកាលានុវត្តភាពច្រើនគួរឲ្យកត់សំគាល់ តាមរយៈពាណិជ្ជកម្មអន្តរជាតិក្តី ក៏នៅមានបញ្ហាប្រឈមធ្ងន់ធ្ងរជាច្រើនដែរ រាប់ទាំង កំណើននៃវិសមភាពនៅក្នុង និងក្នុងចំណោមសង្គមផ្សេងៗ។

ដោយការសង្កត់ធ្ងន់របស់វាទៅលើការធានាឲ្យមានលទ្ធផលប្រកបដោយយុត្តិធម៌ តាមរយៈការផ្តល់ការងារកាន់តែច្រើន ពង្រីកការការពារសង្គម ជំរុញកិច្ចសន្ទនាក្នុងសង្គម និងសម្រេចឲ្យបាននូវការគោរពគោលការណ៍ និងសិទ្ធិជាមូលដ្ឋាននៅកន្លែងធ្វើការ "សេចក្តីប្រកាសពីយុត្តិធម៌សង្គម ដើម្បីសកលភាវូបនីយកម្មមួយប្រកបដោយយុត្តិធម៌" ក្នុងឆ្នាំ២០០៨ របស់ ILO បានឲ្យយើងធ្វើការពិចារណាកាន់តែខ្លាំងបន្ថែមទៀត ដើម្បីផ្តល់អត្ថន័យដល់ពាក្យស្លោកថា "ប្រសិនជាអ្នកចង់បានសន្តិភាព ត្រូវសាបព្រោះយុត្តិធម៌"។

អង្គការ ទីភ្នាក់ងារ និងអ្នកជំនាញការឯករាជ្យទាំងអស់របស់អង្គការសហប្រជាជាតិ ត្រូវទទួលខុសត្រូវក្នុងការបញ្ជ្រាបយុត្តិធម៌សង្គមទៅក្នុងវិធីសាស្ត្រ និងសកម្មភាពរបស់ខ្លួន។ ពិភពលោកមានការហត់នឿយក្នុងការលើកឡើងអំពីសិទ្ធិ សុខភាព សិទ្ធិអប់រំ សិទ្ធិអភិវឌ្ឍ សិទ្ធិការងារ និងសមភាពយេនឌ័រ ដោយមិនឃើញមានវិធានការអនុវត្តជាក់ស្តែងនោះ។ យើងត្រូវសន្យាធ្វើការងារនេះដោយសាមគ្គីគ្នា និងត្រូវផ្តោការយកចិត្តទុកដាក់លើស្ថានភាពជាក់ស្តែង ដោយធានាថាយុត្តិធម៌សង្គមកើតមានពិតប្រាកដសម្រាប់មនុស្សគ្រប់រូបដោយមិនមានការរើសអើង។

ក្នុងបរិបទនេះ វាដាច់ខាតដែលថាប្រព័ន្ធសេដ្ឋកិច្ចសកល ត្រូវតែចាក់ឫសយ៉ាងជ្រៅនៅក្នុងគោលការណ៍យុត្តិធម៌សមធម៌ លទ្ធិប្រជាធិបតេយ្យ មានការចូលរួម តម្លាភាព គណនីយភាព និងការរាប់បញ្ចូល ដូចមានចែងក្នុងសេចក្តីសម្រេចឲ្យបង្កើតឲ្យមានទិវាពិភពលោកស្តីពីយុត្តិធម៌សង្គមនេះឡើង។"

**ចប់**

*លោក អាល់ហ្វេដ ដឺ ហ្សាយ៉ាស (Alfred de Zayas) (សហរដ្ឋអាមេរិក) ត្រូវបានក្រុមប្រឹក្សាសិទ្ធិមនុស្សតែងតាំងជាអ្នកជំនាញការឯករាជ្យដំបូងបង្អស់ទទួលបន្ទុកការលើកស្ទួយសណ្តាប់ធ្នាប់ប្រជាធិបតេយ្យ និងសមធម៌អន្តរជាតិ ក្នុងខែឧសភា ឆ្នាំ២០១២។ បច្ចុប្បន្នលោកជាសាស្ត្រាចារ្យផ្នែកនីតិអន្តរជាតិនៃសាលាការទូតហ្សឺណែវ។ លោក ដឺ ហ្សាយ៉ាស មានជំនាញផ្នែកនីតិក្រុមហ៊ុន និងច្បាប់គ្រួសារ នៅទីក្រុងញូវយ៉ក និង រដ្ឋហ្លូរីដា។ ក្នុងនាមជាអ្នកកាន់អណត្តិរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស លោកធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបម្រើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់គាត់។ សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖* http://www.ohchr.org/EN/Issues/IntOrder/Pages/IEInternationalorderIndex.aspx

*អ្នកជំនាញការឯករាជ្យគឺជាផ្នែកមួយនៃអ្វីដែលគេស្គាល់ថាជានីតិវិធីពិសេសរបស់ក្រុមប្រឹក្សាសិទ្ធិមនុស្ស។ នីតិវិធីពិសេស (ស្ថាប័នដ៏ធំបំផុតមួយនៃអ្នកជំនាញការឯករាជ្យនៅក្នុងប្រព័ន្ធអង្គការសហប្រជាជាតិ) គឺជាឈ្មោះទូទៅនៃយន្តការឃ្លាំមើលនិងស្វែងរកការពិតឯករាជ្យរបស់ក្រុមប្រឹក្សានេះ ដែលលើកអំពីស្ថានភាពរបស់*

*ប្រទេសមួយជាក់លាក់ ឬតាមវិស័យនីមួយៗនៅគ្រប់តំបន់ទាំងអស់នៃពិភពលោក។ អ្នកជំនាញការរបស់នីតិវិធីពិសេស ធ្វើការឈរលើគោលការស្ម័គ្រចិត្ត ពួកគាត់មិនមែនជាបុគ្គលិក អ.ស.ប ទេ ហើយក៏មិនទទួលប្រាក់បៀវត្សរ៍សម្រាប់ការងាររបស់ពួកគាត់ដែរ។ ពួកគាត់ធ្វើការឯករាជ្យពីរដ្ឋាភិបាល ឬអង្គការណាមួយ ហើយបំរើការក្នុងសមត្ថភាពបុគ្គលផ្ទាល់របស់ពួកគាត់។*

*សំរាប់ព័ត៌មានបន្ថែម និង**ការសាកសួរព័ត៌មានផ្សេងៗ** សូមមេត្តាទាក់ទងមក៖ លោក ធីបូត ហ្គីលឡេ (Thibaut Guillet) តាមរយៈទូរស័ព្ទលេខ (+៤១ ២២ ៩១៧ ៩៣ ៤៩/tguillet@ohchr.org) ឬសរសេរមកកាន់ ie-internationalorder@ohchr.org*

សិទ្ធិមនុស្ស អ.ស.ប ស្វែងយល់ពីយើងលើបណ្តាញព័ត៌មានសង្គម ៖
ហ្វេសប៊ុក៖ https://www.facebook.com/unitednationshumanrights
ទ្វីតធឺ៖ http://twitter.com/UNrightswire
ហ្គោហ្គល៖ **Google+** gplus.to/unitednationshumanrights
យូធូប៖ http://www.youtube.com/UNOHCHR